# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**
**លេខ.០៥/១៧.នព**

## សេចក្តីថ្លែងការណ៍
## របស់
## អ្នកនាំពាក្យ ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា

ក្រសួងការពារជាតិ សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងដល់ចំណាត់ការរបស់សមត្ថកិច្ច ដែលបានចាប់ខ្លួនបុគ្គលឈ្មោះ កឹម សុខា ប្រធានគណៈបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១៧ ។

ក្រសួងការពារជាតិចាត់ទុកថា ការនិយាយផ្ទាល់មាត់និងសកម្មភាពរបស់បុគ្គលឈ្មោះ កឹម សុខា ជាអំពើខុសច្បាប់ មានលក្ខណៈជាបទឧក្រិដ្ឋជាក់ស្តែង ក្បត់ជាតិ ប៉ះពាល់យ៉ាងខ្លាំងដល់សន្តិសុខជាតិ និងមានបំណងផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់។

ក្រសួងការពារជាតិ សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងដល់រាជរដ្ឋាភិបាលស្របច្បាប់ ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដាច់ខាតមិនឲ្យមានអំពើបដិវត្តន៍ពណ៌ និងការឃុបឃិតជាមួយបរទេស ប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ដែលកើតចេញពីការបោះឆ្នោត និងត្រូវបានអន្តរជាតិទទួលស្គាល់ថា ជារដ្ឋាភិបាលស្របច្បាប់តែមួយគត់របស់ព្រះរាជាណាចក្រកម្ពុជា និងសុំឲ្យតុលាការផ្តន្ទាទោសបុគ្គលឈ្មោះ កឹម សុខា ព្រមទាំងបក្សពួកយ៉ាងធ្ងន់ធ្ងរបំផុត។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ខែកញ្ញា ឆ្នាំ ២០១៧*

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh